**OMI0012**

# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្ភាសន៍ជាមួយ សោម ចាន់ ភេទប្រុស អាយុ៦១ឆ្នាំ

## មុខងារសម័យខ្មែរក្រហមៈ យោធា

## សព្វថ្ងៃរស់នៅភូមិទំនប់លើ ឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

## ខែសីហា ឆ្នាំ២០១១

## សម្ភាសន៍ដោយៈ ផាត កុសល

**០០:៥៤:៣១**

**២៣ទំព័រ**

កុសល : ចុះទើបបានក្នុងភូមិម៉ាចំនួន ថ្ងៃនេះចុះមកបាន២ភូមិ ប៉ុនចុះមកមាថ្ងៃទៀត បានគ្រប់ៗ ជាគោលការណ៍ ខ្ញុំសួរឈ្មោះរបស់លោកពូពេញ?

ចាន់ : ឈ្មោះ សោម ចាន់ៗ

កុសល : មានឈ្មោះអីផ្សេងទៀតទេ?

ចាន់ : អត់មានៗ

កុសល : ពូចាំថ្ងៃកំណើតទេ?

ចាន់ : ចាំៗ

កុសល : ថ្ងៃទីប៉ុន្មាន ខែប៉ុន្មាន ឆ្នាំប៉ុន្មាន?

ចាន់ : ទី៥ ៗ

កុសល : ខែប៉ុន្មាន?

ចាន់ : ៥ ៗ

កុសល : ៥ដែរ ឆ្នាំប៉ុន្មាន?

ចាន់ : ១៩៥១ ៗ

កុសល : ដំណាលឪពុកខ្ញុំដែរ ៗ ទីកន្លែងកំណើត?

ចាន់ : កំណើតខ្ញុំកើតភូមិតាម៉ូង ខាងតាកែវ ៗ

កុសល : តាម៉ូង ហើយត្រម៉ូង?

ចាន់ : តាម៉ូងៗ

កុសល : ឃុំ?

ចាន់ ៖ ឃុំព្រៃផ្គាំ ។

កុសល ៖ ស្រុក?

ចាន់ ៖ ស្រុកពីដើមគេដាក់ព្រៃកប្បាស ឥឡូវគាត់ដាពីរ ។

កុសល ៖ ពីដើមព្រៃកបា្រស ដាក់តាមពីដើម ។ ព្រៃកប្បាស ខេត្តតាកែវ ។ អាស័យដ្ឋានបច្ចុប្បន្ន ភូមិទំនប់លើ ត្រពាំងប្រិយ៍ អន្លង់វែង ឧត្តរមានជ័យ ។ ខ្ញុំអ្នកសៀមរាបដែរតើ ។ ដើម្បីសួរទាក់ទងនឹងការផ្សះផ្សា យើងចង់ដឹងថា លោកពូបានដឹងអ្វីខ្លះពីមុនមក ការតស៊ូ ខ្ញុំសុំរំលឹកតំបន់ព្រឹត្តិការណ៍មួយ គឺព្រឹត្តិការណ៍ពេលមុនឆ្នាំ៧៥ ជាពិសេសពេលសម្តេចឪត្រូវបានពួកលន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់ ១៨ មិថុនា(មិនា) ឆ្នាំ១៩៧០ ។ ពូចាំព្រឹត្តិការណ៍ហ្នឹងបានទេ?

ចាន់ ៖ កាលហ្នឹងខ្ញុំនៅក្មេងដែរ ។

កុសល ៖ ប៉ុន្តែធ្លាប់ឮសួរទេ?

ចាន់ ៖ អាចរបៀប១៦ ១៧ នៅចាំបានតើ ។ លន់ នល់ ធ្វើរដ្ឋប្រហារថ្ងៃទី១០ប៉ុន្មាន ខែប៉ុន្មានទេ?

កុសល ៖ ១៨ មិថុនា(មិនា) ១៩៧០ ។ ចឹងពេលនឹងលោកពូនៅរៀននៅឡើយ?

ចាន់ ៖ ខ្ញុំឈប់ហើយ ១៦ឆ្នាំ ខ្ញុំឈប់រៀន ។

កុសល ៖ ក្នុងពេលនោះ គ្រួសារលោកពូយ៉ាងម៉េចដែរ?

ចាន់ ៖ គ្រួសារខ្ញុំពីដើមឡើយ?

កុសល ៖ បាទ! ជីវភាពគ្រួសារ ក្រ មធ្យម បង្គួរ មាន?

ចាន់ ៖ ជីវភាពគ្រួសារខ្ញុំពីដើម គឺក្រ ។

កុសល ៖ បាទ! កសិករក្រីក្រ?

ចាន់ ៖ គាត់ហូបមិនគ្រប់គ្រាន់ ។

កុសល ៖ តើពេលដែលពួកអាមេរិចកាំងទម្លាក់គ្រាប់បែកនឹង មានត្រូវភូមិឃុំ មានប៉ះពាល់ដល់ភូមិឃុំយើងដែរ?

ចាន់ ៖ ប៉ះនៅកន្លែងទីចាត់ការឃុំ និយាយរួមប្រជុំជននៅនឹងជុំវិញឃុំ មន្ទីរឃុំ ឧទាហរណ៍ថាឃុំនេះវាមានសាលាឃុំ វាទម្លាក់ប៉ះ ។ ជំនាន់ឆ្នាំ៧០ វៃជាមួយពួកយួនចុះមកពីវៀតណាមខាងត្បូង ជាមួយចលនា និយាយរួមជំនាន់នឹង គេចលនាតស៊ូខ្លួនមួយទេ ។

កុសល ៖ ត្រូវហើយកាលពេលនឹងពួកយួនចូលមកខាងត្បូង?

ចាន់ ៖ ពួកយួនចូលមកពីខាងត្បូងចូលមក ពួកហាណូយមកជួយខាងនេះ ពួកយៀកកុង រ៉ៃគ្នានៅនោះ ។

កុសល ៖ ចឹងពូបានឃើញព្រឹត្តិការណ៍នឹងកើតឡើងនៅតំបន់ហ្នឹង?

ចាន់ ៖ ខ្ញុំឃើញ ខ្ញុំដើរប្រមូលខ្មោចទៀតផង កាលខ្ញុំនៅធ្វើខ្ញុំអត់ទាន់មានខ្លាចអ៊ីទាំងអស់ ព្រោះអត់ទាន់ដឹងអី ។ ដឹងដែរ តែចាស់ៗគាត់ឆ្ងល់ថា យើងហ៊ានចូលព្រោះវាដកទ័ព ខ្ញុំទៅមើលមនុស្សងាប់ប៉ុន្មាន ខ្ញុំដឹង ជំនាន់ហ្នឹង ។

កុសល ៖ ពេលនោះ ពូមានអារម្មណ៍ម៉េចដែរ ឃើញព្រឹត្តិការណ៍អស់នឹង បើតាមពូមើល?

ចាន់ ៖ កាលនោះដូចអត់មានកើតទុក្ខអី រៀងសប្បាយមិនដែលព្រួសរគ្រាប់សូរកាំភ្លើង ចុះនៅក្មេងៗមិនទាន់ចេះគិតអី ដឹងថាហូបបាយហើយ ទៅមើលគោប៉ុននោះ មកពីគោចូលផ្ទះ ។ ហើយដល់ពេលចលនានេះវាគាបសង្កត់ខ្លាំងដែរ ប៉ុនគេថា តស៊ូដើម្បីយកសម្តេចឪ ចូលព្រៃម៉ាគីម៉ាគា ក៏យើង ។

កុសល ៖ ចឹងព្រួការអំពាវនាវតស៊ូ ដើម្បីយកសម្តេចឪ?

ចាន់ ៖ បាទ! គេឲ្យដើម្បីចូលរួមចូលព្រៃម៉ាគីម៉ាគា ដើម្បីយកសម្តេចឪមកវិញ នេះក៏ ។

កុសល ៖ ចឹងនេះជាមូលហេតុមួយ ដែលពូសម្រេចចិត្តចូល?

ចាន់ ៖ មូលហេតុតែប៉ុននឹងទេ ដែលខ្ញុំចូលនឹងតស៊ូនឹង ។ ហើយក៏មិនចាប់អារម្មណ៍ថា តស៊ូមកដល់៧៥ ដែលយើងរំដោះភ្នំពេញហើយ មិនមានថាវាមានបក្សកុម្មុយនីស ខ្ញុំអត់ប៉ាន់ស្មានមិនត្រូវ ។

កុសល ៖ ក៏មិនដឹងដែរពេលនឹង?

ចាន់ ៖ មិនដឹងទេ ដឹងថាចលនាតស៊ូយកសម្តេចឪ ។ ហើយដល់ពេលសម្តេចឪចូលស្រុក ដែលយើងបានកម្ពុជាប្រជាធិបតេយ្យឯករាជ្យមក ក៏យើងមិនទាន់ថាបានឯករាជ្យពេញលេញដែរជំនាន់នោះ ។ គេនៅប្រកាសក្នុងរបបគេ គឺកម្ពុជាប្រជាធិបតេយ្យ ចូលរួមទង់ចលនាតស៊ូនឹង បានគេបង្កើតបក្សកុម្មុយនីស ដឹកនាំប្រទេសកម្ពុជា មានប៉ុល ពត, អៀង សារី, ខៀវ សំផន អីនឹង ក៏យើង ធម្មតាយើងជាប្រជាជននៅក្រោមរណបរបស់គេ យើងចេះតែនៅរួមរស់ យើងមិនដឹងទៅណាទៀត ។

កុសល ៖ រត់គេចក៏មិនកើត ។

ចាន់ ៖ បាទ! រត់ទៅណាក៏មិនកើត ។ ជំនាន់ហ្នឹងខ្ញុំធ្វើទាហាននៅឡើយ ។

កុសល ៖ ធ្វើទាហាននៅឡើយ?

ចាន់ ៖ បាទ!

កុសល ៖ ធ្វើទាហាននៅណា? គេបញ្ជូនទៅណា?

ចាន់ ៖ ធ្វើទាហាន កាលនឹងគេឲ្យនៅទីក្រុងភ្នំពេញ ។

កុសល ៖ បន្ទាប់ពីរំដោះហើយ គេបញ្ជូនឲ្យមកភ្នំពេញ?

ចាន់ ៖ បាទ!មកការពារទីក្រុងភ្នំពេញ មុំសំយ៉ាប់ខ្ទញយើងនេះ ខាងលិចភ្នំពេញ មុំពោធិ៍ចិនតុង តាំងក្រសាំង អន្លង់ក្ងាន នៅនឹងរយៈ ។

កុសល ៖ ការពារខ្មែរក្រវ៉ាត់ភ្នំពេញ?

ចាន់ ៖ បើយើងរំដោះភ្នំពេញថ្ងៃទី១៧មេសា ៧៥ ខែ១១ ខ្ញុំនឹងឡើងមករតនគិរីវិញ គេដូរ ។

កុសល ៖ គេដូរឲ្យឡើងមករតនគិរី?

ចាន់ ៖ បាទ! មករតនគិរីវិញ ។

កុសល ៖ ចឹងសុំត្រឡប់ក្នុងរយៈពេលប៉ុន្មានខែ ដែលពូនៅនឹង?

ចាន់ ៖ គិតមើល ។

កសល ៖ ខែ១១ ចឹងប្រហែលជា៥ខែ ៦ខែ?

ចាន់ ៖ អាច៦ខែយើងវិលទៅរតនគិរី ។

កុសល ៖ ពេលក្លាមៗនឹង ព្រឹត្តិការណ៍ទីក្រុងភ្នំពេញយ៉ាងម៉េចដែរ? មានឃើញមនុស្សចេញមកច្រើនទេ?

ចាន់ ៖ ទេ! កាលនឹងអត់ទាន់មានបញ្ហាទេ ស្ងាត់ល្អ គេដកកងពល៨០១ឡើងមកការពារព្រំដែនវៀតណាម នៅយើងរតនគិរី កាលនឹងវាអត់ទាន់មានសភាព ។

កុសល ៖ ពូឃើញមនុស្សជម្លៀសចេញមក?

ចាន់ ៖ អត់ទេ! កាលពីយើងរំដោះ១៧មេសា ជម្លៀស ចេញមកគ្រប់ ភាគច្រើនឯរាប់ខាងលិចខាងផ្លូវកំពង់ឆ្នាំង យើងឡើងមកខាងបាត់ដំបងច្រើនមែន ។ ហើយយើងទៅតាមទន្លេមេគង្គទៅក្រោម ភាគតិចទេ សំខាន់មកភាគខាងលិចច្រើន ។ គេរំដោះភ្នំពេញ ដើម្បីយកប្រជាជនចេញពីភ្នំពេញមកជនបទវិញ ។ នេះខ្ញុំនៅទីក្រុងភ្នំពេញហើយ ។

កុសល ៖ ចុះក្រោយមកទៅរតនគិរី?

ចាន់ ៖ ខែ១១មករតនគិរី ដូចមិនមានសភាពការណ៍អីទេ វាធម្មតា ។

កុសល ៖ ហេតុអីបានគេបញ្ជូនលោកពូទៅខាងនោះ?

ចាន់ ៖ គេដូរកងពល ៧៨០១ឡើងមកការពារព្រំដែនរតនគិរីវិញ ។

កុសល ៖ ចឹងកាលនោះលោកពូនៅកងពល៨០១ គេឲ្យបញ្ជូនមករតនគិរីវិញ?

ចាន់ ៖ បាទ!

កុសល ៖ សភាពការណ៍ខាងនោះយ៉ាងម៉េចទៅ?

ចាន់ ៖ នៅណា?

កុសល ៖ នៅរតនគិរី ធូរស្រាលជាងមុនឬក៏?

ចាន់ ៖ នៅរតនគិរី កាលពីឆ្នាំ៧៦នេះ គឺវាមានសភាពប្រទាញប្រទុងតាមព្រំដែន ។

កុសល ៖ ជាមួយនឹងប្រទេស?

ចាន់ ៖ ប្រទេសវៀតណាម ។

កុសល ៖ ហើយបាន៧៧បានខ្លាំង?

ចាន់ ៖ ៧៧ខ្លាំងហើយ អានឹងនៅវ៉ៃដាក់គ្នាតាមព្រំដែន ។

កុសល ៖ ចឹងលោកពូនៅក្នុងពេលនឹងបានចូលរួមក្នុងការការពារប្រទេសក្នុងការវ៉ៃជាមួយប្រទេសវៀតណាមទេ ពេលនឹង?

ចាន់ ៖ ចូល ។

កុសល ៖ ហើយខាងស្លាប់របួសច្រើនទេ ពេលនឹងកងពលនៅក្នុងកងពលរបស់ពូ?

ចាន់ ៖ ទេ! កាលនឹងអត់ទាន់មានស្លាប់ទេ វាមានត្រឹមរបួសខ្លះ ប៉ុនបើស្លាប់ៗនឹងមីនយួនចុច ។ អានឹងស្លាប់មែន ប៉ុនវ៉ៃគ្នាក្នុងសមរភូមិ អត់មានបញ្ហាអីទេ មិនដែលឃើញអ្នកស្លាប់ មិនដែលឃើញអ្នកមានដែលរបួសតិចតួច ធម្មតាទេយើងបង់សំណាញ់ ម៉េចក៏មានប៉ះ ១-២មិនខានទេ ធម្មតាជាប់សម្រាស ។

កុសល ៖ បើក្នុងរយៈពី៧៦ ៧៧ មានការជោគជ័យ ពីពេលវ៉ៃហ្នឹង?

ចាន់ ៖ វ៉ៃឈ្នះ ។

កុសល ៖ មានបានវ៉ៃចូល?

ចាន់ ៖ បាទ! វ៉ៃចូលរហូតដល់ព្រំដែន អាខ្លះចូលដល់ក្រុងនគរ ដល់ចុងក្រោយគេវាត់ដល់ខាងទន្លេមេគង្គនេះវិញ ខាងភូមិភាគបូព៌ាវិញ ។

កុសល ៖ ដល់ហើយចាញ់ស្មាយរៀង ហើយនឹងព្រៃវែងទៅវិញ?

ចាន់ ៖ បាទ!

កុសល ៖ ចឹងខាងក្រចេះ ពួកពូខាងនោះឈ្នះ?

ចាន់ ៖ ខាងនោះអត់ទាន់មាន ដល់គេរំដោះភ្នំពេញបានប្រហែលជាកន្លះខែ បានយើងដកទ័ពតាមព្រំដែនរុលចូលព្រៃ ។

កុសល ៖ ប៉ុន្តែមិនដែលចាញ់ពីមុនមក?

ចាន់ ៖ មិនចាញ់ទេ មិនបាក់ទ័ពទេ ។

កុសល : ចាញ់ៗបូព៌ទេ?

ចាន់ : បាទ! ចាញ់ពីភូមិភាគបូព៌ដែលគេយកភ្នំពេញបាន អានឹងយើងក៏ៗ

កុសល : ដកមកវិញមក?

ចាន់ : ដកចេញតាមសវត្តិភាព អានឹងយុទ្ធវិធីរបស់យើង ដើររកក្តួច រកដំឡូង រកអង្ករ តាមភូមិ ហូបបណ្តោះៗខ្លួនមកៗ

កុសល : ក្នុងពេលវ៉ៃជាមួយវៀតណាមពេលនឹង លោកពូនៅកាន់ការអី វរៈសេនាតូច ធំ?

ចាន់ : ខ្ញុំកាន់អនុសេនាតូចៗ

កុសល : អនុសេនាតូច?

ចាន់ : បាទ!

កុសល : អនុសេនាតូចប៉ុន្មាននាក់?

ចាន់ : គ្នា៣០នាក់ៗ

កុសល : ចឹង១កងពល៨០១ច្រើន?

ចាន់ : ហ៊ើ! កងពលច្រើនរាប់ពាន់នាក់នឹង យក៣-៤វរសេនាធំនោះៗ

កុសល : ពូកាន់ម៉ាកងពលតូច?

ចាន់ : ខ្ញុំត្រឹមអនុសេនាតូច ៣០នាក់ៗ

កុសល : ចុះពេលធ្វើការវ៉ៃលុកជាមួយវៀតណាមនឹង ដូចថាលោកពូពេលនឹង បានចូលទៅដល់ប្រទេសវៀតណាម បានវ៉ៃឈ្នះចូលទៅដល់ក្នុងវៀតណាមផ្ទាល់?

ចាន់ : ចូលតើៗ ប៉ុនវ៉ៃឈ្នះ មិនមែនវ៉ៃឈ្នះយើងឈ្នះទេ វិធីដែលយើង...ៗ

កុសល : យើងវ៉ៃហើយ យើងដកមកវិញ...?

ចាន់ : វ៉ៃដកចេញវិញៗ

កុសល : ហើយដកចេញវិញ?

ចាន់ : បាទ!

កុសល : អត់នៅទេ?

ចាន់ : អឺ! គ្រាន់វ៉ាថាដូចសង្គ្រាមឈ្លប វ៉ាដាក់ទ្រុបហើយយើងនាំគ្នាមកវិញ នៅចាំ...ៗ

កុសល : ចុះក្រោយមកគេឡូដកពេលវៀតណាមវ៉ៃ?

ចាន់ : ដកមកវៀតណាមកៗ នៅទឹកដីយើងវិញៗ

កុសល : ហើយយើងត្រឡប់មកវិញ ត្រឡប់មកខាងនេះ?

ចាន់ : មកយើងនៅអូរត្របែកៗ

កុសល ៖ ធ្វើដំណើរយ៉ាងម៉េច? ជិះអីមក

ចាន់ ៖ ហា៎! គ្មានជិះអី ដើរ ។

កុសល ៖ ដើរមកដល់ព្រំដែន?

ចាន់ ៖ បាទ! ដើរអន្តរម៉ាទៃ ជួនណាបាយពូបនៗនេះ ដើរមក ហេវត្រឹមណាក៏ហូបត្រឹមនេះ ដេក ។

កុសល ៖ ដល់ត្រឹមណា ដេកត្រឹមហ្នឹង?

ចាន់ ៖ បាទ! ដល់ក្រោយមកគ្មានរូងគ្មានទីតាំងណា យើងនៅតាមព្រៃ តាមព្រំដែន ធម្មតា យើងមានជំពុះតាមព្រំដែន ។

កុសល ៖ ហើយយើងមកនេះ មានចូលរួមការពារព្រំដែនជាមួយថៃ?

ចាន់ ៖ ខ្ញុំហ៎! ទេ!វាគួររំលឹកវាធ្វើប្រជាជនធម្មតាទេ ប៉ុន្តក្នុងអារម្មណ៍របស់ខ្ញុំវាឈឺចាប់ដែរ ចំពោះថៃឈ្លានពាន មិនមែនថាយើងជាប្រជាជនអត់យល់សភាពការណ៍ អាងតែរត់លូន អត់ទេ ។ គឺឈឺឆ្អាលណាស់ ព្រោះខ្ញុំពីដើម ខ្ញុំអ្នកធ្វើសង្គ្រាមជាមួយលន់ នល់ ជាមួយ អាមេរិច ជាមួយយួនអីវាមានប៉ុន្មានដំណាក់កាលជាប់គ្នារហូត ។ ដល់មកពេលបច្ចុប្បន្ន ថៃ ក៏វាក្តៅក្រហាយណាស់ដែរ មិនធម្មតាទេ ព្រោះវាមិនទាន់បានឯករាជ្យពិតប្រាកដ យើងមិនទាន់យកអំបែង យកគ្រាប់ចេញពីខ្លួនអស់ បង្កើតសង្គ្រាមណាទៀតនេះ ព្រួយ បារម្ភ ហើយនឹងឈឺចាប់ដែរនឹង ។

កុសល ៖ មើលទៅតាមលោកពូយល់ទៅ យើងចេះតែថាម៉ារយៈជម្លោះនេះ គឺថាពួកអតីតគឺថា ក្លាហានជាង យកទៅដាក់នៅជួរមុខទាំងអស់ ។ មូលហេតុអីបានថា ពួកអតីតហ្នឹងដូចពូ យឹម គុនអី ឥឡូវគាត់ទៅជា?

ចាន់ ៖ ទេ! អានេះខត្តមគតិស្នេហាជាតិ ។

កុសល ៖ ហេតុអីបានគាត់ដឹងៗល្បិចរបស់ថៃ ធ្លាប់ធ្វើការជាមួយថៃពីមុនមក?

ចាន់ ៖ អូ!អានេះមុននឹងចូលផ្តាច់ជាមួយរដ្ឋាភិបាល តាអី គាត់បានណែនាំយើងដែរ គាត់ណែនាំ ថាអស់ពីពួកអញទៅកម្ពុជាចូលក្នុងសហព័ន្ធឥណ្ឌូចិនហើយ ។ ហើយនឹងអាចប្រទេសជិត ខាងឈ្លានពាន ។ ឯងចងចាំនោះ ម៉ាជីវិតឯង ទម្រាំឯងងាប់ក៏បានយូរដែរ ។ ហើយក្នុង អារម្មណ៍យើង គឺគាត់ផ្តាំដូចជាម៉ែឪយើងទូន្មានកូនចឹង ។ ចឹងយើងចេះចាប់អារម្មណ៍ទៅ តើរឿងនេះពិត ឬមិនពិត ។

កុសល ៖ ចង់និយាយថា ប៉ុល ពត, តាម៉ុក?

ចាន់ : បាទ! ដល់ចុងក្រោយ ដូចគាត់ថាមែន តាម៉ុកៗ កាលពីដើមគាត់នៅលើភ្នំ អត់មានអ្នកណាឈ្លានពានទឹកដីគាត់ស្អាតណាស់ ត្រឹមដីត្រឹមប៉ុន្មាន គាត់ការពារត្រឹមនឹងៗ

កុសល : ដូចហួសតិច ដូចជាពើយទៅខាងនោះ?

ចាន់ : បាទ! ឥឡូវមាត់ពើយ តាមខ្ញុំពិនិត្យមើលកាលពីខ្ញុំនៅ នោះនៅវង់ទី២ ទី៣ទៅក្នុង ដល់មកបច្ចុប្បន្ននេះ រំកិលចង់ធ្លាក់ព្រំ ធ្លាក់លើភ្នំហើយឥឡូវហ្នឹងៗ គេវាស់តម្លង៤-១០-២០ម៉ែត្រ ហើយដូច្នេះខុសដូវពីជំនាន់តានោះឆ្ងាយណាស់ៗ ខ្ញុំពិនិត្យមើលជំនាន់នោះត្រង់ណា ខ្ញុំមិនចេះដឹងទេៗ

កុសល : ចុះក្រោយមកទៀត លោកពូធ្វើជាប្រជាជនធម្មតាៗ ហេតុអីបានលោកពូពិការជើង?

ចាន់ : ខ្ញុំពិការជើងតាំងពីឆ្នាំ៨៣ៗ

កុសល : វ៉ៃជាមួយពួកយួន?

ចាន់ : បាទ! វ៉ៃនៅបៀតព្រះវិហារៗ

កុសល : ចឹងម៉ាដូវនេះ ពូស្គាល់អស់ហើយ ព្រះវិហារ សៀមរាបអី?

ចាន់ : និយាយរួមតាំងពីត្រឹមនេះ ព្រះវិហារ អត់តែទៅក្នុងមិនសូវស្គាល់ទេ ខ្ញុំជំនាន់នោះនៅការពារព្រំដែន ទៅថាឡាបរិវ៉ាត ធ្លាក់ទៅស៊ឹងត្រែង សៀមប៉ាងទៅស្គាល់ធ្លាប់ធ្វើការម៉ាដូវនឹងៗ ប៉ុនស្គាល់វាមិនច្បាស់អស់ទេ ដូចដើរម៉ាដូវលើ យើងស្គាល់ទំនប់លើ ប៉ុនទៅក្នុងទៀត មិនដឹងថាភូមិអីយើងអត់ស្គាល់ទេៗ ដល់ចំនុចណាដែលយើងធ្លាប់ដើរស្គាល់ៗ ព្រោះម៉ាដូវនេះ ខ្ញុំដើរមករាប់ខែតាំងពីរតនគិរីមក ដើររហូតៗ

កុសល : ចុះពេលដែលធ្វើសមាហរណកម្ម ពេលហ្នឹងលោកពូមកជាមួយម៉ាក្រុមមុន បក៏ក្រោយ?

ចាន់ : ខ្ញុំចុះមកជាទ្រង់ទ្រាយទាំងអស់គ្នាម៉ង់ៗ

កុសល : ទាំងអស់គ្នាម៉ង់?

ចាន់ : បាទ! ជាមួយបងប្អូនប្រជាជនទាំងអស់ៗ

កុសល : ជាមួយបងដាណា?

ចាន់ : ដាណា គេផ្តាច់ខ្លួនដេរ្សងៗ

កុសល : ខ្ញុំអត់យល់?

ចាន់ : កាលនឹងខ្មែរក្រហមវាមាន២ផ្នែក កាលយើងនៅដំបូងប៉ុល ពត ហើយនឹងតាម៉ុកគាត់ឈ្មោះគ្នា លោកដាណា គាត់នៅក្រោមបទបញ្ជារបស់តាដែរៗ ដល់ចុងក្រោយគេវ៉ៃគ្នាគាត់ផ្តាច់ទៅរាជរដ្ឋាភិបាលមុន ២ផ្នែកៗ គាត់ទៅចឹង ពួកខ្ញុំដល់គេវ៉ៃគ្នាខ្លាំង ខ្ញុំឡើងទៅលើ ទៅដំរំ ពូណយៗ គេសមាហរណកម្មបានយើងមកជួបគ្នាដដែលៗ

កុសល : ទាំងអស់ដដែល?

ចាន់ : បាទ!

កុសល : ចុះតានៅអី ជាមួយតាដែរ?

ចាន់ : តានៅ ចុះមកជាមួយពួកខ្ញុំ ។

កុសល : ចុះតាពឹម និងបងផាណា គាត់មកមុន?

ចាន់ : តាពឹម និងបងផាណា គេចេញទៅតាតាប់ ។

កុសល : អ្នកមកមុនដូចបានកាន់អំណាចធំ?

ចាន់ : បាទ! ធម្មតាអានឹងគេផ្តាច់ខ្លួនមុនយើងៗក្រោយគេ ។

កុសល : ចឹងគ្រួសារលោកពូក្នុងជំនាន់ពត្នាំមានបាត់បង់ទេ?

ចាន់ : គ្រួសារខ្ញុំ?

កុសល : បាទ!

ចាន់ : អូ! និយាយពីបងប្អូនមានបាត់ច្រើនដែរនឹង ។

កុសល : តែគ្រួសារផ្ទាល់ខ្លួនអត់អីទេ?

ចាន់ : តែគ្រួសារខ្ញុំអត់ទេ ។

កុសល : បងប្អូនច្រើន?

ចាន់ : ព្រោះចេះ កាលនឹងយើងនិយាយទៅរបបប៉ុលពត យើងអត់បានរស់នៅក្នុងសង្គមសហករណ៍អីទេ ខ្ញុំនៅតែជួរកងទ័ពរហូត ។ ហេតុដូច្នេះ បងប្អូនខ្ញុំមាននៅនឹងទីក្រុង ដល់ពេលគេជម្លៀស បងប្អូនណាទៅនៅខេត្តណា ស្រុកណា គឺទៅវិញ ។ ដល់សម័យ៧៩ នេះ មិនពួកវៀតណាមចូលមកៗគេត្រូវសំរិតពួក១៧មេសា គេកំណត់១៧មេសា ពួកសមត្ថភាពមិនល្អ ។ បងប្អូនខ្ញុំស្លាប់ជាប់ប្រហែលជា២-៣គ្រួសារអស់ទាំងពូជៗវ៉ៃចោលចឹងម៉ង ។

កុសល : ហើយលោកពូអត់ដឹងទេ ពេលនឹង?

ចាន់ : ខ្ញុំអត់ដឹងអីទេ ខ្ញុំទើបចុះឆ្នាំ២០០០ បានខ្ញុំចុះទៅលេងស្រុក បានខ្ញុំសួរប្រវត្តិសាស្ត្រថាណាបងប្អូនខ្ញុំទៅណាអស់ ។ ម៉ែខ្ញុំថាមិនបាច់សួរទេ នាំ គាត់ខ្លាចខ្ញុំចិត្តឆេវឆាវ ។ ខ្ញុំថាអត់ទេ ពេលនេះខ្ញុំអស់មានអំណាចអីដូចពីមុនហើយ ខ្ញុំជាប្រជាជនអីទេ ខ្ញុំគ្រាន់តែសួរចង់ដឹង ។ គាត់ថាគេយកវ៉ៃចោលអស់ហើយ ។ ខ្ញុំថាមូលហេតុអីបានវ៉ៃចោល ។ គាត់ថាពួក១៧មេសា ។ ចឹងពួកយើងអ្នករំដោះនឹងនៅក្រោមអាណានិគមន៍របស់អ្នកណា មិនប៉ុល

ពតទាំងអស់គ្នា ហេតុអីបានវ៉ៃខ្មែរគ្នាឯងចោល ។ ហេតុដូច្នេះសភាពការណ៍ច្របូលច្របល់ ។

កុសល : ច្របូកច្របល់ អត់មានដឹងអ៊ីដែលគេធ្វើខាងក្នុងយ៉ាងម៉េចៗ?

ចាន់ : អត់មានសណ្ដាប់ធ្នាប់ ច្បាប់ទម្លាប់ មេក្រុមក៏វ៉ៃកូនទាហានបាន ប្រជាជនវ៉ៃប្រធានភូមិ វ៉ៃបងប្អូនអ្នកភូមិចោលបាន ដូច្នេះវាច្បាប់អាណាធិបតេយ្យ ។

កុសល : ចឹងខ្ញុំសួរបញ្ជាក់បន្តិច លោកពូដឹងថាមានការកាប់សម្លាប់ក្រោយមកទេ? ក្នុងឆ្នាំណាពូដឹង?

ចាន់ : ក្រោយទេ ខាងសម្លាប់ខ្ញុំឆ្លើយមិនរួចម៉ង បើសួររឿងខាងសម្លាប់ ខ្ញុំឆ្លើយអត់រួច ។

កុសល : ប៉ុនចាប់ផ្ដើមដឹង ពេលណាដឹង?

ចាន់ : ដឹងៗ ខ្ញុំចុះទៅសមាហរណកម្មហើយ ទៅលេងស្រុកបានដឹង ។

កុសល : ចឹងរហូតដល់៩៨នេះ បានដឹងថាមានរបបកាប់សម្លាប់នឹងមក?

ចាន់ : បាទ! ខ្ញុំដឹងពីឆ្នាំមើល៧៧ ៧៨ ៧៩ ដែលខ្ញុំពួរ៉ាដ្យូគេប្រកាស យួនចូលស្រុកគេចាប់ផ្ដើមហើយ ថារបបប៉ុល ពត កាប់សម្លាប់ប្រជាជនក្នុងសហករណ៍សហគមន៍អី ខ្ញុំក៏ចាប់ដឹង ម៉េចក៏សម្លាប់ បើកងទ័ពនៅជួរនៅនឹងមុខ ដូច្នេះអូ!វាពិបាកនិយាយណាស់ ។

កុសល : ចឹងក្រោយមករឿងការកាប់សម្លាប់របប ប៉ុល ពត លោកពូទើបដឹងដូចពេលក្រោយដល់ពេលសមាហរណកម្ម ពេលទៅដល់ស្រុកភូមិទៅបានដឹងបាត់បងប្អូនប្រជាជនអត់ដឹងថាពីមុនមកអត់ដឹងសោះថាគេធ្វើចឹង?

ចាន់ : អត់ដឹងទាល់តែសោះ ព្រោះខ្ញុំនៅតាមព្រំដែនរហូត ។

កុសល : បើឮពីឆ្នាំ៧៩មក ស្មានថាគេប្រកាសនយោបាយ ពួកខាងវៀតណាមគេចេះ?

ចាន់ : មានការរីកចំរើន ឮសួរថាសហគមន៍អីដួយអរដែរ បាយរួមផ្សំជាមួយគ្នាហូបនេះហូបនោះ មិនដឹងសហគមន៍រលាយរូប ។

កុសល : បាទ! ចេះធ្វើតាមតែគេទៅ?

ចាន់ : បាទ!

កុសល : ដូចថាជីវិតរបស់ពូឆ្លងកាត់មកច្រើន ទី១ចូលតាំងពីក្មេងមកចូលបដិវត្តន៍តាំងពីក្មេង នឹកឃើញបម្រើប្រទេសជាតិល្អវិញ បំបាត់អំពើពុករលួយ របបលន់ នល់ អាមេរិចរហូតមក ។ និយាយរួមដាក់ដូចជាខ្សែជីវិត ហាក់ដូចជាខ្លួនឯងតស៊ូ មិននឹកស្មានថាបងប្អូននៅក្រោយនឹងគេសម្លាប់ រហូតដល់ពូពិការទៀត ។ សំនួរដែលសំខាន់ដែលខ្ញុំចង់ចូលនោះគឺថាធ្វើយ៉ាងម៉េចទៅឲ្យមានការផ្សះផ្សាជាតិ? ចំនុចចង់និយាយមុននឹងខ្ញុំចង់បញ្ជាក់គឺថា

សាច់រឿងស្តាប់ពីខាងក្រៅ មកដល់ស្តាប់សាច់រឿងរបស់ពូហាក់ដូចជាដូរចត់មួយដែរ ។ ស្តាប់ទៅបងប្អូននៅខាងក្នុងដែលបាត់បង់គ្រួសារនោះ គាត់ថាគាត់ឈឺចាប់ម្យ៉ាងរបស់គាត់ដែរ ។ ដូច្នេះ វាមានកន្ទុយមានក្បាល មានក្នុងមានក្រៅ សាច់រឿងវាមាន២ ខ្ទះតស៊ូដូចគ្នា ។ រឿងនឹងចំនុចមួយដែលខ្ញុំតែងតែដូចថាព្យាយាមពិចារណា ចង់ដឹង ។ ចឹងធ្វើម៉េចទៅចឹង ដើម្បីឲ្យប្រទេសយើងមានការផ្សះផ្សាជាតិ មានសន្តិភាពទៅមុខ ។

ចាន់ : ទេ! ជំនាន់នឹងដូចខ្ញុំមិនយល់ដែរគ្រូ បើសិនជាប្រទេសយើងមិនទាន់ ពួកនេះមិនទាន់សមាហរណកម ខ្ញុំថានៅមិនចប់សង្គ្រាមទេ ព្រោះពួកខ្មែរក្រហមនេះមិនមែនធម្មតាទេ អ្នកដឹកនាំនេះគឺខ្លាំងណាស់ ។ ហើយយើងគំនិតថា យើងចង់បានណាស់រឿងឯករាជ្យ ចង់បានមែនទែន ។ ហើយជំនាន់ហ្នឹងសង្គ្រាម ថ្ងៃណាក៏ថ្ងៃឃើញតែលីកាំភ្លើងចូលទៅដឹងថាថ្ងៃស្លាប់ហើយ ម៉ាថ្ងៃស្លាប់ ម៉ាថ្ងៃរស់ ។ ហើយនេះជីវិតយើងមិនមែនថាដោតលក់ក្នុងផ្សារ ប៉ុនយើងទៅធ្វើការយើងប៉ុនប្រមាណខ្លួនយើងដែរ ថាថ្ងៃនេះគឺលីកាំភ្លើងចេញទៅសមរភូមិដឹងថាស្លាប់ ។

កុសល : ក្នុងទសវត្សរ៍៨០ ?

ចាន់ : បាទ! ប៉ុនមិនដឹងស្លាប់ម៉ោងណានាទីណាយើងអត់ដឹងដែរ បានរស់ម៉ាយប់ណា ស្អែកឡើងគឺទន្ទេញអានឹង ស្លាប់ទៀតហើយស្អែក ។

កុសល : ពូនៅចាំពេលថ្ងៃដែលពូជាន់មីនហ្នឹង?

ចាន់ : ខ្ញុំចាំតើ ថ្ងៃទី១៩ ខែ៨ ឆ្នាំ១៩៩៣ ។

កុសល : ចឹង៩៩៣នេះហើយ?

ចាន់ : ៩៣ សមាហរណកម្មពួកអ៊ុនតាកលចូលនេះ ។ ពីជំនាន់អ៊ុនតាក់ចូលហើយ យើងធ្វើសកម្មភាពខ្លាំង ។

កុសល : ចុះជាន់មីននៅកន្លែងណា?

ចាន់ : នៅលើភ្នំ ។

កុសល : ពួកណាដែលដាក់?

ចាន់ : ជាន់មីនស្គរ អូ!អាមីនច្រើនណាស់មិនដឹងពួកណាដាក់ យើងក៏ដាក់ គេក៏ដាក់ វាពិបាកប៉ាន់ប្រមាណមិនដឹងមីនខាងណា ខាងហ៊ុន សែន ក៏គេដាក់មីន យើងក៏ដាក់ ។ ជំនាន់នឹងយួនប្រើមីនច្រើនណាស់តាមព្រំដែន ហើយសព្វថ្ងៃក៏គេដោះមិនទាន់អស់ តាមព្រំដែន ។ ហើយរកសន្តិភាពនេះ ។

កុសល : ថ្ងៃនឹង លោកពូទៅណា?

ចាន់ ៖ អឺ! ទៅធ្វើទាហានតើ ។

កុសល ៖ ទៅវៃនៅកន្លែងណា បានដើរជាន់មីន?

ចាន់ ៖ នៅការពារភ្នំព្រះវិហារហ្នឹង ។

កុសល ៖ នៅព្រះវិហារហ្នឹង?

ចាន់ ៖ ព្រោះកាលនឹងរាជរដ្ឋាភិបាលនៅលើភ្នំ ហើយពួកខ្ញុំនៅពីកើតភ្នំនៅមើលអន្តេតគ្នាទៅវិញទៅមក ៣-៤ថ្ងៃក៏បាញ់គ្នាគេចរៀងខ្លួនទៅ ។

កុសល ៖ នៅប្រាសាទនឹងម៉ង?

ចាន់ ៖ បាទ! រដ្ឋាភិបាលនៅប្រាសាទ ខ្ញុំអត់មានបន្ទាយមានប៉ុស្តិ៍អីនឹងគេទេ នៅតាមព្រៃ ។

កុសល ៖ ការផ្សះផ្សា ធ្វើម៉េចឲ្យផ្សះផ្សាគ្នាបាន?

ចាន់ ៖ ចុះឥឡូវក្រែងគេផ្សះផ្សាគ្នាហើយ ។

កុសល ៖ ដូចពូថាចឹងក៏បាន ផ្សះផ្សាមែន តែដូចថាមុនដំបូងគេចាប់យករបួសនឹង វាចាប់ផ្តើមផ្សះផ្សា តើលោកពូយល់ថាផ្សះផ្សាបានអសហើយឬនៅ?

ចាន់ ៖ ភាសាផ្សះផ្សាអានឹង ។

កុសល ៖ តើដំបៅនឹងវាជាអស់ហើយនៅ? មួយចាប់ផ្តើមផ្សះផ្សា ប៉ុន្តែមកដល់ថ្ងៃនេះ ពូថាផ្សះផ្សានេះវាជាសះអស់ហើយឬនៅ ឬក៏នៅមានរបួសខាងក្នុង?

ចាន់ ៖ ឥឡូវដូចថាវាជាហើយ ។

កុសល ៖ ចំពោះលោកពូជាអស់ហើយ?

ចាន់ ៖ ជាអស់ហើយ ប៉ុនថាជាក្នុងភ្នែកខាងរាជរដ្ឋាភិបាលដែលយើងមើលជារូបភាពចំហទេណា ប៉ុនបើផ្ទៃក្នុងខ្ញុំថាវាមិនទាន់ជា ។

កុសល ៖ ខ្ញុំគិតថាចឹងដែរ ។

ចាន់ ៖ មិនទាន់ជាទី១ អ៊ីដែលខ្ញុំចោទធ្ងន់ ទី២លើច្បាប់ៗដូចថាមានច្បាប់ដែរ ដូចអនាធិតេយ្យ ។ ឥឡូវយើងនិយាយពីបញ្ហាចោរឆក់ប្លន់ កាំភ្លើងបាញ់សម្លាប់ ស្តាប់វិទ្យុគឺព័ត៌មានរាល់តែព្រឹកនឹង ឆាប់ដន្លែរប្លន់រហូត ។ ប៉ុនចោរវាចាប់មិនចេះអស់ ចាប់ណាស់ កើតណាស់ ។ អានឹងខ្ញុំយល់ថា វាមិនទាន់មានភាពឯករាជ្យពេញលេញទេ ។

កុសល ៖ ពីក្នុងមកក៏នៅតែមានការស្រពេចស្រពិល ជាពិសេសអ្នកដែលរងគ្រោះបាត់ ស្លាប់គ្រួសារជំនាន់ហ្នឹង ចេះទៅមើលដូចថា ខ្ញុំឧទាហរណ៍មួយ អ្នកខាងក្នុងចេះតែគិតថាឧបមាថានិយាយអន្លង់វែង គេគិតមកតំបន់អី អ្នកព្រៃ អ្នកក្រៅច្បាប់ ។ កាលដែលខ្ញុំផ្ទាល់ឃើញ វាផ្សេង ហ្នឹងខ្ញុំលើកឧទាហរណ៍មួយ ។ ដូច្នេះ ចំពោះខ្ញុំមានការភ័ន្តច្រឡំ

សង្គមយើងនៅមានការយល់ច្រឡំ មិនទាន់យល់ពីគ្នាទៅវិញនៅឡើយ មិនដឹងជាលោកពូយល់ស្រប ឬយ៉ាងម៉េច?

ចាន់ : ឥឡូវនឹងវាចេះ អានឹងច្បាប់ពីតុលាការវិញ ព្រោះខ្ញុំទៅប្រជុំថ្ងៃមុន លោកអភិបាលស្រុកក៏គាត់និយាយដែរ គាត់ថាបងប្អូនទាំងអស់គ្នាកុំភ័យពីរឿងគេចាប់០១ ០២ ០៣ ០៤ ០៥ គាត់ថាមិនបាច់ទេ គេយកតែប៉ុននឹងទេ។ យើងកុំភ្ញាក់ផ្អើលអីទៀត។ ប៉ុនបងប្អូនខ្លះ ដែលមានតួនាទីពីដើមរឿងចំណាស់សំផឹក៏នៅរៀងព្រួយបារម្ភដែរ។ ហើយចំពោះខ្ញុំអត់មានភ័យមានភិត ព្រោះខ្ញុំអត់មានតួនាទីអីទៅកាប់សម្លាប់ពីណា គ្រាន់ផ្នែកខាងយោធាប៉ុននឹង។ ប៉ុនបងប្អូនយើងខ្លះវាភិតភ័យ ខ្លាចអស់អា០១ ០២ ០៣ទៀត វាបន្តទាំងអស់ អានឹងព្រួយបារម្ភដែរ។ បើខ្ញុំចិត្តខុសគេ បើថាគេយកទាំងអស់ក៏យកទៅចំណាស់នេះហើយ យកទៅធ្វើអីធ្វើទៅ ព្រោះអានឹងយើងថាពាក់ព័ន្ធរបបនយោបាយរបស់ខ្មែរ។ បើរាជរដ្ឋាភិបាលពេញចិត្តឲ្យពួកអន្តរជាតិគេយកទៅៗ ម៉ាដំណើរតាមផ្លូវច្បាប់។

កុសល : ប៉ុន្តែបើតាមចិត្តលោកពូដូចថា ដើម្បីសន្តិភាព ដើម្បីផ្សះផ្សា យើងគួរតែមិនបន្តប្រឫកប្របល់?

ចាន់ : មិនឲ្យ បញ្ចប់តែម្តង វាអស់ប៉ុននឹង ល្មមអស់ចិត្តហើយ។

កុសល : ឲ្យកាត់តែមេៗនឹងទៅតុលាការនឹង?

ចាន់ : បាទ!

កុសល : ចំនុចមួយនឹងក៏សំខាន់ដែរ?

ចាន់ : អានឹងបើយើងកាត់ទោសតែអៗនឹង ក៏វាចូលផ្នែកនយោបាយ ក៏ជាប់នឹងហ៊ុន សែនដូចគ្នា។ ចុះខ្មែរក្រហមដូចគ្នាតើ អតីតដូចគ្នា ហេង សំរិន, ហ៊ុន សែន, ជា ស៊ីម នឹងសុទ្ធតែអតីតទាំងអស់នឹងឯង។ សុទ្ធតែពួកនឹងទាំងអស់ ប៉ុនយើងមិននិយាយដល់ម្លឹងពេកទេ ព្រោះគេអ្នកដឹកនាំ ព្រោះគេអ្នកដឹកនាំ ប៉ុនអានេះក្អួយមកសម្អាសន៍ ខ្ញុំឆ្លើយម៉ង កុំឲ្យស្រពិចស្រពិល។ ខ្ញុំនិយាយមុខពីណាក៏ខ្ញុំនិយាយដែរ ថារឿងកាត់ទោសអុំៗហើយអស់ចូលដល់០ប៉ុន្មានក៏ចាប់ហ៊ុន សែន ទៅដែរ អានឹងបានឯកភាព ព្រោះហ៊ុន សែន គាត់អ្នកនាំយួនចូលប្រទេសបានសម្លាប់ប្រជាជនច្រើន មិនមែនតែចោទប្រកាន់ដូចខ្មែរក្រហមណា ខ្មែរក្រហមណាមានតួនាទីទៅកាប់សម្លាប់ អានឹងខ្ទាំងបង្កប់ស៊ីរូងផ្ទៃក្នុង បំភ្លើសពីមាគ៌ាថា ប៉ុល ពត ថាយើងរៀបចំដាំបាយដាំអីឲ្យហូប វាអត់អីដាំយើងឲ្យដាំបបរហូប អានឹងវាមិនបំភ្លើសមាគ៌ា។

កុសល :	ចឹងពូយល់ថាជំនាន់៣ឆ្នាំ ដែលការកាប់សម្លាប់ច្រើននឹង គឺដោយសារពួកវៀតណាមកវា បំភ្លើសច្រើនដែរ?

ចាន់ :	បាទ! អានឹងវាបំភ្លើសទៅបំភ្លើសមកទេ បើនិយាយពីគោលការណ៍របស់ប៉ុល ពត គាត់គ្មានគំនិតអីឲ្យកាប់សម្លាប់ គ្រាន់តែគុកគ្មានដាក់ផងនោះ ត្រង់គាត់នោះវាអត់ច្បាប់រស់នៅសង្គមតូចមួយប៉ុនវាអត់មានចែងច្បាប់ កុងសង្គមតូចដែលគាត់កាន់កាប់អំណាចនោះ ។

កុសល :	ចុះក្រោយមក...គេហៅខ្ញុំទៅមើលដូចថាគុកទួលស្លែង ។

ចាន់ :	ខ្ញុំទៅមើលដែរតើ ។

កុសល :	ពូជឿថា តើសង្គមនឹងមានធ្វើចឹងដែរអត់?

ចាន់ :	ខ្ញុំជឿខ្លះ មិនជឿខ្លះ ជឿភាគតិច ។ អានឹងខ្ញុំសម្គាល់មើលក្នុងរបបកម្ពុជាប្រជាធិបតេយ្យមិនមែនអ្នកណាយកមនុស្សទៅវ៉ៃចោលក្នុងរណ្តៅៗ ដូចជំនាន់បេ៥២ទម្លាក់ប្រជាជន ប្រមូលដាក់រណ្តៅ ខ្ញុំជឿភាគតិចណាស់ ។ ប៉ុនសង្គមនោះវាច្របូកច្របល់ យើងក៏កាន់កាប់ប្រទេសខាងនោះក៏ចូលមក វាធ្វើឲ្យច្របូកច្របល់ ដល់ចុងក្រោយបំផុតចោទប្រកាន់ ប៉ុល ពត អ្នកកាប់សម្លាប់ទាំងអស់ ។ អានឹងខ្ញុំទស្សនៈខ្ញុំទេ ។

កុសល :	ភាពច្របូកច្របល់ច្រើន?

ចាន់ :	បាទ! ភាពច្របូកច្របល់ ហើយបុគ្គលិកជារួមទៅគាត់មិនដែលមានមាត៌ាណាចែងឲ្យទៅកាប់ប្រជាជនរាប់លាន រាប់សែន ដូចគេផ្សាយវ៉ាដ្យូដាក់ក្នុងគុកទួលស្លែង រូបភាពដាក់ស្តែងទេ ខ្ញុំនិយាយវា ជឿតិចណាស់ ១០ខ្ញុំជឿ១ ។ អានឹងខ្ញុំទៅទស្សនៈកិច្ចបានម៉ាថ្ងៃដែរ ។

កុសល :	គេឲ្យទៅ?

ចាន់ :	គេឲ្យទៅក្បាលដាក់ឡើងគរលើទូឡើងរាប់គ្រួច ។

កុសល :	ខាងណាគេឲ្យទៅ?

ចាន់ :	ខាងពួកកន្ទ្វេងតុលាការខ្មែរក្រហមនឹង ។

កុសល :	ទៅប៉ុន្មានថ្ងៃ?

ចាន់ :	ទៅម៉ាយប់ ម៉ាថ្ងៃមកវិញ ។

កុសល :	លោកពូចាប់អារម្មណ៍យ៉ាងម៉េចដែរ ការស្នាក់នៅ?

ចាន់ :	ទេ! រឿងចាប់អារម្មណ៍ៗ តែយើងមិនសូវជឿ ។

កុសល :	ស្នាក់នៅម៉េច?

ចាន់ ៖ ស្អាក់នៅគេមិនឲ្យដេកទេ ទៅពីនេះម៉ោង៩យប់ ទៅដល់ភ្នំពេញភ្លឺៗ គេចាប់ផ្ដើមនាំទស្សនកិច្ចកន្លែងណាទួលស្លែង ណាគេធ្វើទារុណកម្មៗ កន្លែងណាគេធ្វើប្រដាប់បង្ហាញយើង ដល់នេះគេនាំចូលសវនាការកាត់ទោស ។

កុសល ៖ ពូមានអារម្មណ៍ម៉េដែរពេលនឹង?

ចាន់ ៖ ទេ! អារម្មណ៍វាគ្មានបញ្ហាអីទេ ធម្មតា ។

កុសល ៖ ឃើញអីខ្លះពេលនឹង?

ចាន់ ៖ អត់មានឃើញអីទេ ឃើញតែពួកគេប្រធាននៅនឹង គេមកសរនាំយើងតិចតួចហ្នឹង ។ គេថាចង់ជួបអ៊ំៗដែរ ។ គេថាភាគច្រើនយើងចង់ជួប ។ ប៉ុន្តែចុងក្រោយមកដូចថាអត់បានជួបទេ ព្រោះអ៊ំៗអត់សូវស្រួលក៏គេឲ្យមកវិញមក គេជូនឡានមកដល់អន្លង់វែងវិញ ។ បានប៉ុននោះហើយតើ គ្មានទៅណាទៀត អានឹងទម្លាក់កន្លែង...គេឲ្យយើងចូលមួយភ្លែតចូលកន្លែងកាត់ទោសនឹង ។

កុសល ៖ គេឲ្យទៅដល់ជើងឯក?

ចាន់ ៖ ចូល ។ បឹងជើងឯកអត់បានទៅទេ ។

កុសល ៖ ទៅបានទួលស្លែង?

ចាន់ ៖ ទួលស្លែង ហើយនឹងកន្លែងតុលាការគេ ។

កុសល ៖ ដូចលោកពូថាជឿខ្លះមិនជឿខ្លះ កន្លែងមិនជឿត្រង់ណា?

ចាន់ ៖ កន្លែងមិនជឿត្រង់ថាវាមនុស្សងាប់ច្រើនពេក វាហួសការប៉ាន់ប្រមាណរបស់យើងក្នុងសមរភូមិយើងវ៉ៃរាប់សិនឆ្នាំ ក៏មិនដល់ពលិកម្ម ក៏មិនដល់យកក្បាលមកគរដូចដំបូកដែរអត់ទេ ។

កុសល ៖ កន្លែងនឹងគេទម្លាក់ទៅលើឌុច?

ចាន់ ៖ ហ្នឹងហើយតា ឌុច គាត់មានកំហុសអី រឿងតាឌុច គាត់អ្នកការពារកន្លែងសន្តិសុខជិតនឹងដល់ចុងក្រោយគាត់រកអីមិនកើត សុខចិត្តទទួលកំហុសយកម៉ង់ទៅ យើងនៅប្រកែកអីពេក បើយើងនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យហើយនឹង ។

កុសល ៖ ទទួលកំហុសម៉ង់?

ចាន់ ៖ បាទ! ទទួលកំហុសម៉ង់ កុំឲ្យវាយូរ ។

កុសល ៖ ចឹងលោកពូយល់ថា ដូចថាគាត់ធ្វើតាម ក្រោមគេដែរចឹង?

ចាន់ ៖ បាទ!

កុសល ៖ ចឹងគាត់ទទួលកំហុសទៅ ពូយល់ថាតើការកាត់ទោសគាត់នឹងដូចថាមានយុត្តិធម៌ទេ?

ចាន់ ៖ ទេ! ខ្ញុំ ។

កុសល ៖ គេឲ្យជាប់១៩ឆ្នាំ ៣៥ឆ្នាំ?

ចាន់ ៖ ខ្ញុំយល់អយុត្តិធម៌ មិនមានភាពយុត្តិធម៌ជូនគាត់ទេ ព្រោះរបបកម្ពុជាប្រជាធិបតេយ្យ វាមានដូចម្រាមដៃយើងវាមានថ្នាក់ទី១ ទី២ ទី៣ ។ ឧុចនៅក្រោមគេ ប៉ុនថាគាត់ទទួលបន្ទុកក្នុងការពារពួកមានសមាសភាពមិនល្អ គាត់ទទួលគ្រប់គ្រងពិតមែន ប៉ុនបើកាប់សម្លាប់មិនដល់ម្លឹងពេកទេ ។ អានឹងតាមអារម្មណ៍ដែលខ្ញុំយល់ វាមិនដល់នឹងទេ ។

កុសល ៖ ឧបមាថាគាត់មានខុសខ្លះ?

ចាន់ ៖ ខុស វាអ្នកល្អប៉ុនណាក៏វាមានដឿងរៀកមួយដែលត្រូវខុសខ្លះដែរ ។

កុសល ៖ ប៉ុន្តែគាត់ធ្វើតាមបញ្ជាគេដែរ តើគាត់គួរទទួលកំហុស?

ចាន់ ៖ បាទ! បញ្ជាគេ ប៉ុនបទបញ្ជាក៏រស់នៅក៏មិនមានបទបញ្ជាណាកាប់មនុស្សដល់ប៉ុននេះ ព្រោះខ្ញុំនៅជាប់ៗជាមួយតាៗ មិនឆ្ងាយពីតាប៉ុន្មានទេ គ្រាន់ចេញពីនោះដល់ពួកខ្ញុំការពារ អង្គរក្សការពារ ដូចថាការពារផងវៃផង ។

កុសល ៖ តាម៉ុក?

ចាន់ ៖ បាទ! ប៉ុនវាមិនដល់ម្លឹងទេ ។

កុសល ៖ គាត់ជាមនុស្សម៉េចទៅ?

ចាន់ ៖ មនុស្សតា ហ៎!មនុស្សគាត់អួតអាងៗនឹង គាត់ជួនកាលបើនិយាយអ្នកជិតខាងគេខ្លាចណាស់ ។ ប៉ុនដេរស្តីហៅចូល អត់មានដេរៗម៉ោកៗ នេះឯងយកលុយចាយ ហៅស៊ីអស់ហើយ ។ ប៉ុនយើងអ្នកមិនដឹងរឿងគាត់ថាគាត់កាច ប៉ុនដល់យើងរស់នៅជិតធម្មតាគាត់មក គាត់ដេរអានេះអានោះបេះចុះមានអីឲ្យហូបអស់រលីង ធម្មតា ។

កុសល ៖ មាត់អាក្រក់?

ចាន់ ៖ មាត់អាក្រក់ ។

កុសល ៖ មួយទៀតទាក់ទងទៅនឹងអ្វីដែលខ្ញុំជួបមក ខ្ញុំឃើញនៅស្រុកអន្លង់វែងនេះ ទោះបីពិការក៏ដោយ ទោះបីដាច់ជើង២ក៏ដោយ មនុស្សមិនមានការសុំទានទេ ។ ខ្ញុំឆ្ងល់ថាពូពន្យល់ខ្ញុំតិចគេពន្យល់មកថាទាក់ទងនឹងសេដ្ឋកិច្ចមានឫសមានគល់? ពូពន្យល់ខ្ញុំតិច ថាហេតុអីបានតំបន់នេះខុសគេ?

ចាន់ ៖ ព្រោះខ្ញុំយល់ឃើញ អានេះគោលគំនិតខ្ញុំក៏អ្នកពិការដែរ ហើយអ្នកពិការទាំងអស់គ្នាសុទ្ធតែមានដី ហើយអ្នកពិការខ្លះមានឡាន២-៣គ្រឿងដាក់ផ្ទះ ។ ហេតុច្នេះ គោលគំនិតនៅអន្លង់វែង បើតាមខ្ញុំដើរមើលទីរួមផ្សារ ចំពោះអ្នកពិការអត់មានដើរសុំទានទេ មានតែ

អ្នកដើង២មានខ្លះ មិនអត់ទេ មានខ្លះ មានអីចាស់ៗអីគាត់ដើរសុំទានអីនឹង។ បើចំពោះអ្នកពិការសុទ្ធគឺអត់ទេ ព្រោះគេមានទឹកមានដី មានដីផ្ទះមានដីធ្វើស្រែចិញ្ចឹមជីវិតគេបានហើយការងារគេៗ ហើយទី២អ្នកខ្លះដាច់ដើង២ គេចេះទៅធ្វើរោងសិប្បកម្ម ធ្វើតាមតម្លៃម៉ាថ្ងៃគេឲ្យប៉ុន្មានចេះតែនាំគ្នាធ្វើទៅ អានឹងពួកពិការនៅភូមិនេះតិចណាស់ បើភូមិស្រះឈូកបានច្រើន អ្នកពិការ ដាច់ដើង២ក៏មានៗ ហើយដូច្នេះ អ្នកពិការស្រុកនេះគេមានតម្លៃកិត្តិយសរបស់គេណា គេខំប្រឹងការងារគេណាស់ ទោះបីដាច់ដើង២ក៏គេខំៗបើម្នាក់ទៀតខ្ញុំប្រាប់គ្រូឲ្យត្រង់ ដាច់ដើង២ ដាច់ម៉ាចំហៀងទៀត ហើយធ្វើប៉ោតលក់បានទៀតៗ ប៉ោតយើងពីដើម យើងមិនមែនប្រើធុងស្បែតត្រូទេ យើងវៃដែកធម្មតាធ្វើប៉ោតលក់ឲ្យគេបានដៃម៉ាចំហៀង។

កុសល : នៅណាគាត់ឥឡូវ?

ចាន់ : ឥឡូវគាត់ទៅរតនគិរីបាត់ហើយ រតនគិរីតាំងពីសមាហរណកម្ម។

កុសល : ចឹងដល់ពេលលោកតាវិញមនុស្សគាត់ចិត្តល្អ គាត់កសាងច្រើន គាត់ជឿទៅលើសេដ្ឋកិច្ចមិនចឹង?

ចាន់ : បាទ!

កុសល : លោកពូរៀបរាប់មកហាក់ដូចជាផ្អត់គំនិតនឹងៗ ចឹងពូនៅជិតគាត់បានប៉ុន្មានឆ្នាំ? ពូស្គាល់គាត់ច្បាស់?

ចាន់ : ខ្ញុំនិយាយរឿងស្គាល់ហើយ អ៊ំខៀវ សំផន ក៏ខ្ញុំស្គាល់ តាប៉ុល ពត ក៏ខ្ញុំស្គាល់ដែរ ប៉ុនមិនបានរស់នៅឆ្ងាំងបាយជាមួយគាត់។

កុសល : ចឹងលោកពូនៅធ្វើអង្គរក្សឲ្យតានឹងបានប៉ុន្មានឆ្នាំ?

ចាន់ : ខ្ញុំធ្វើខ្ញុំទើបនឹងធ្វើខ្ញុំដាច់ដើងនេះទេ ហើយអង្គរក្សក៏មិនមែនអង្គរក្សផ្ទាល់ដែរ នៅឆ្ងាយដែរ ដូចគាត់នៅលើ ខ្ញុំនៅក្រោមគេ ប៉ុនអង្គភាពក្នុងក្រសួងមន្ទីរជាមួយគ្នា។

កុសល : បានចុះដាប់ជាមួយគាត់?

ចាន់ : មើលពី៩៣មករហូតដល់២០០០វែងដែរ... តិចដែរ។

កុសល : ប៉ុននៅក្នុងអំឡុងនឹងបានស្គាល់គាត់ច្បាស់?

ចាន់ : ស្គាល់ច្បាស់ ធ្លាប់គាត់ទិញម្ហូបអាហារ។

កុសល : ចុះខៀវ សំផន គាត់នៅណា?

ចាន់ : អ៊ំខៀវ សំផន ក៏នៅនឹងដូចគ្នា ពេលសមាហរណកម្មពួក អៀង សារី ផ្តាច់ខ្លួនពីប៉ៃលិនគាត់រត់មកនៅនេះ។

កុសល ៖ ពីប៉ៃលិនមកនៅនេះ?

ចាន់ ៖ មកនេះ ទាំងខៀវ សំផន, ប៉ុល ពត, នួន ជា, មកមូលគ្នាទាំងអស់ ។

កុសល ៖ លើភ្នំ?

ចាន់ ៖ បាទ! ប៉ុនកន្លែងខៀវ សំផន នៅក្បែរនឹងផ្លូវ តាគាត់ចល័តចុះឡើងពេញតែវាលនៅក្រោមខ្លះ នៅលើភ្នំខ្លះ ។

កុសល ៖ ពេលនឹងគាត់មានទស្សនៈយ៉ាងម៉េច ពេលធ្វើសមាហរណកម្ម ខ្ញុំឮថាជាពិសេសតាគាត់ អីង អ្នកណាដែលផ្តាច់ខ្លួនទៅ គាត់ថាចាប់មនុស្សយកមកមានសម្លាប់ចោល ឮផ្តាច់ខ្លួន?

ចាន់ ៖ ទេ! អានឹងវាផ្សេងមួយទៀត អានឹងជារឿងទស្សនៈរបស់ខ្ញុំយល់ដែលគាត់បានណែនាំយើង កាលពីពួកនឹងផ្តាច់ខ្លួន ហើយគេវៃចូលយើងនេះ តាគាត់ផ្តាំថា ពួកឯងមិនបាច់ឡើងលើទេ វាអត់ងាប់ទេ ចុះចូលរាជរដ្ឋាភិបាល ព្រោះយើងចាញ់គេហើយ ។ ប៉ុនមានជនក្បត់មួយដែលវានៅកប់ស៊ីរុងផ្ទៃក្នុងនឹង វាដេញឲ្យយើងឡើង ។ ខាំ ងួន ឥឡូវគេចាប់ដាក់គុកនៅភ្នំពេញបាត់ហើយ ។ ដេញទៅឲ្យយើងឡើងអស់ មកវិញ គេវៃផ្ទះសម្បែងស្រូវអង្ករយើងចាក់ចោលពេញវាល ។ ហេតុដូច្នេះ យើងទៅរយៈប៉ុន្មានខែ មិនដល់ម៉ាឆ្នាំមកវិញអត់បាយ ។

កុសល ៖ អត់បាយអត់ទឹក?

ចាន់ ៖ បាទ!ចុះអង្ករគេយកស្រូវអស់ហើយ សូម្បីតែផ្ទះគេទុកតែជើងតាងឲ្យ គេរុះគេខ្ទេចអស់ អានឹងទស្សនៈតានឹងគាត់មិនចង់ថាអី ឲ្យយើងលំបាកជាមួយគាត់ទេ ។ គាត់ថា ចង់នៅផ្ទះពីណាអ្នកនឹងនៅទៅ ព្រោះយើងនៅគ្នាច្រើន មិនមែននៅឪពុកកូន២-៣នាក់តាំងពីអន្លង់វែងមកនោះ ។ ដល់វាមានខ្មាំងស៊ីរុងផ្ទៃក្នុង ដេញឲ្យយើងឡើងទៅៗ ផ្លោងដាក់ទៀតរបួសប៉ុន្មាននាក់ ។ ប៉ុនគាត់និយាយហើយថា យើងចាញ់គេហើយឃើញទេ អត់មានរឿងឈ្នះទេ ព្រោះពួកតាពឹម ពួកតាផាណា ផ្តាច់ខ្លួន ។ ហើយយើងចាញ់គេនៅសល់ប៉ុន្មាន ថាពួកក្រសួងមន្ទីរគាត់នឹង គ្មានអ្នកណាធ្វើអីកើត ។

កុសល ៖ គ្មានអ្នកវៃអ្នកអីណា?

ចាន់ ៖ អ្នកវៃ អ្នកការពារក្បែរៗនឹងតិចតួច ។ ដល់យើងឆ្នាំ៩៧ ៩៨យើងចុះមកតាផ្តាំដែលថាយើងរស់នៅចូលក្នុងរាជរដ្ឋាភិបាល សង្គមគេនឹងគឺរបៀបផ្សារផងនឹតហើយ យើងទៅម្នាក់ឯងយល់យើង ប៉ុនគាត់ហាមដាច់ខាតធ្វើម៉េចឲ្យមានដីមានទឹក សេដ្ឋកិច្ចមានបុសមានគល់ ។ ហើយបើពួកឯងទៅសូម្បីតែអំបិលក៏អត់ស៊ីដែរ ដូចមាត់គាត់ថាមែន ខ្ញុំមកមុនដំបូងអត់មានលុយមិនទាន់មានចាយ ទម្រាបានលុយរាជរដ្ឋាភិបាលមានចាយ យើង

រហេមរហាមដើររកគេរកឯងអំបិលអីក៏អត់មាន ។ កាលជំនាន់តានោះ អត់ខ្វះទេ អំបិលប្រហុក គាត់ចែកឲ្យរហូតអង្ករអីៗ ខោអាវស្លៀកពាក់អីគាត់ចែកឲ្យគ្រប់ ម៉ាឆ្នាំគាត់ចែកឲ្យ ២ដង ហើយអង្ករម៉ាខែម្ដង ។

កុសល : ចុះថវិកាបានមកពីណាមកពេលនឹង?

ចាន់ : ថវិកា បើនិយាយពីថវិកាចប់ហើយ ។ កាលពីសមាហរណកម្មហើយ បងប្អូនដើរប្រូតស្បូវធ្វើស្បូវធ្វើអីលក់ ម៉ាកណ្ដប់២រៀល ៣រៀល ក៏បានលុយបេះសន្សំខ្វះ ទិញអីហូបខ្វះទៅណា ធ្វើស្រូវធ្វើស្រែខ្វះៗក៏បានលក់ទៅ ម៉ាគីឡូ៣០០-៤០០រៀលលុយខ្មែរយើង ។ ខ្វះក៏មានលុយទិញគោ ទិញអីចិញ្ចឹមយកលក់ដូរយកលុយកាក់ខ្វះ ។

កុសល : ចឹងទាក់ទងនឹងតុលាការដូចពូបានទៅ ហេតុអីបានគេធ្វើចឹង?

ចាន់ : ទេ! អាតុលាការនឹង ខ្ញុំយល់វិញអានឹងខាងអន្តរជាតិវិញគេសុំធ្វើ ។

កុសល : ទេ! កាលនឹងបើខាងខ្មែរយើងក៏សុំធ្វើដែរ ។

ចាន់ : ខ្មែរក៏គេ បើយើងអត់លុយសុំគេមកចង់ធ្វើ ។

កុសល : បាទ! លុយខាងគេមែនៗ ហេតុអីដើម្បីឲ្យមានចឹង ធ្វើនៅស្រុកខ្មែរទៀត?

ចាន់ : គាត់ដើម្បីទាមទារ... ។

កុសល : ហេតុអីចាំបាច់មកធ្វើចឹង បើយើងចង់និយាយថា ផ្សះផ្សាជាតិ? ខ្ញុំអត់យល់ដែរ តើពូយល់ថាម៉េច?

ចាន់ : ឆ្លើយមិនរួចដែរអានឹង ខ្ញុំ ។

កុសល : បើយើងនិយាយផ្សះផ្សាជាតិ ហេតុអីបានគេធ្វើចឹង?

ចាន់ : បើចិត្តខ្ញុំវិញ ខ្ញុំបើថាផ្សះផ្សាជាតិ ព្រោះអ៊ំៗនឹងគាត់គ្មាននយោបាយអីតទៅទៀតទេ ព្រោះគាត់ចាស់ៗអស់ហើយ ទុកគាត់នៅចោលកន្លែងគាត់រកស៊ីចិញ្ចឹមជីវិតគាត់ កូនចៅគាត់ អាយុ៧០-៨០នៅប៉ុនណាទៀត ។ ដូច្នេះ ទស្សនកិច្ចរាល់ថ្ងៃ ក៏នៅគួនអាណិតគាត់ដែរ ព្រោះគាត់ចាស់ហើយណា យកទៅដាក់កន្លែងឃុំឃាំង កូនខ្វះក៏ឈឺគ្រុនវាអត់មានការងារពលកម្មអី ដូច្នេះអារម្មណ៍របស់ខ្ញុំក៏មានការចាប់អារម្មណ៍ចំពោះអ៊ំៗដែរ មិនមែនថាស្អប់ខ្ពើមខាងនេះខាងនោះអីអត់ទេ ព្រោះយើងនៅក្រោមរបបវៀតណាមក៏យើងនៅគាំទ្ររបបនោះឯង របបហ៊ុន សែន ដូចគ្នា បើហ៊ុន សែន ធ្វើខុស ខ្ញុំនិយាយថាខុសរបបកម្ពុជាវាផុតទៅហើយឲ្យគាត់ផុតទៅ នៅធ្វើបាបកម្មពៀរគាត់ទៀត ។

កុសល : ចុះចំពោះអ្នកដែលដូចថាជនរងគ្រោះដែលចោទថា ពួកអ៊ំទាំងនោះសុទ្ធតែមានកំហុសជំនាន់ហ្នឹង បានជាគ្រួសាររបស់គេស្លាប់ តើពូចង់ប្រាប់គេថាម៉េច ឲ្យគេយល់?

ចាន់ ៖ អានឹងកំហុសនឹងរបៀបគេមួរបន្ទាប់ទេ បើគាត់ជាអ្នកដឹកនាំ មិនចឹង ។ ឥឡូវខ្ញុំឧទាហរណ៍ ខ្ញុំមួយ ខ្ញុំអ្នកដឹកនាំក្នុងភូមិនេះ គេមិននិយាយបុគ្គល-ខ ធ្វើខុសទេ គេនិយាយពីខ្ញុំ ភូមិ អ៊ំចាន់ អ្នកធ្វើខុស អានឹងជាបសើមអានឹង ។

កុសល ៖ អ្នកដឹកនាំ?

ចាន់ ៖ បាទ! អ្នកដឹកនាំ ។

កុសល ៖ អ្នកដែលធ្វើគឺមិនដឹង?

ចាន់ ៖ បាទ! អ្នកធ្វើគេមិនដឹងថាខ្លួនគេធ្វើខុសទេ ប៉ុនគេមិននិយាយអ្នកធ្វើណា គេនិយាយភូមិអ៊ំចាន់អ្នកធ្វើ ហើយអ្នកនេះមុននឹងដោះស្រាយបាន ទៅបំភ្លឺនោះឃើញបានដឹងថាបុគ្គលនេះទេនៅក្នុងភូមិនេះភូមិនោះ ។ ដូចខ្ញុំចឹងអ្នកឃើញមិនថានេះ គេថារបស់តាម៉ុក តាប៉ុលពត អ្នកធ្វើទៅ អានឹងមិនខុសគ្នាពីរបបហ៊ុន សែន រាល់ថ្ងៃ ។

កុសល ៖ ចំនុចមួយពូថា ពេលពូទៅភូមិស្រុកវិញ ស្រាប់តែដឹងថាបងប្អូនគេធ្វើបាប ស្លាប់ តាមពូយល់អ្នកណាអ្នកធ្វើ?

ចាន់ ៖ នៅក្នុងភូមិខ្លួនឯង ។

កុសល ៖ អ្នកភូមិ?

ចាន់ ៖ បាទ!

កុសល ៖ អ្នកភូមិក្នុងភូមិនឹង?

ចាន់ ៖ បាទ! ខ្ញុំសួរម៉ែគាត់ថា មិនបាច់ចង់ដឹងទេ នៅទីណាស្រុកកើតលិចរបស់ឯង ប៉ុនគាត់មិនបានប្រាប់ឈ្មោះប្រាប់អី ។ ចប់ហើយម៉ែ មិនបាច់និយាយទេ បើមនុស្សវាងាប់ហើយ ធ្វើម៉េចឲ្យវាកើតវិញ ។

កុសល ៖ ចឹងចំពោះពូដូចថារឿងនឹងវាចប់ហើយ បំភ្លេចវាចោលទៅ?

ចាន់ ៖ បាទ!

កុសល ៖ ពូអត់មានទៅរករឿងអីចឹងទៀត?

ចាន់ ៖ អត់ទេ ខ្ញុំមិនទៅរករឿងអីទេ... ។

កុសល ៖ ដូចថារឿងនឹងវាបានកន្លងផុតទៅហើយ?

ចាន់ ៖ បាទ! ឲ្យវាផុតទៅ មិនបាច់ចងកម្មចងពៀរអីទៀត បើយើងទៅរករឿងក៏យើងមិនដឹងមានអីភស្តុតាង បើខ្មោចងាប់បាត់រលួយជាឆ្អឹងទៅអស់ហើយនឹង ។ គ្រាន់បានត្រឹមម៉ារករឿងអាបញ្ហា និងអ្នកវៃ ហើយអ្នកយើងដឹងរឿង ទៅរករឿងគេម៉េចបាន បើគេយក

ទៅដាក់កាត់ក្តីក៏យើងមិនដឹងជាមានអីភស្តុតាង ។ ហើយដូច្នេះ យើងពិនិត្យឃើញថា រឿងផុត ឲ្យវាចេញទៅ នាំបន្តទៀត ។

កុសល ៖ ចុះខ្ញុំសួរចំនុចមួយទៀត ដូចថា ដើម្បីការផ្សះផ្សាដដែល ដូចថាពេលនឹងវាច្របូកច្របល់ លោកពូលើកមកថាវាស្មុគស្មាញច្របូកច្របល់ ហើយលោកពូផ្ទាល់ទៅដល់ស្រាប់តែមានបងប្អូនទៅក្រោយនឹងស្លាប់ ។ ចឹងទេលោកពូយល់ថា ការស្វែងរកពិតអ្វីដែលកើតឡើងចាំបាច់ ឬក៏យើងគួរតែបំភ្លេចចោល?

ចាន់ ៖ ខ្ញុំទស្សនៈខ្ញុំ បំភ្លេចចោល ។

កុសល ៖ មិនបាច់គិតរើកញែកតទៅទៀត?

ចាន់ ៖ អត់មានឆ្កឹះឆ្កាលអីទៀតទេ ចប់ហើយ ចប់ម៉ង អានឹងទស្សនៈខ្ញុំ ។

កុសល ៖ បើថាឆ្កឹះទៅមានបញ្ហា?

ចាន ៖ បាទ! បើថាឆ្កឹះទៅមានបញ្ហា ដូច្នេះឆាប់ហើយទៅតាមដំណើរអ្នកឆាប់ ។

កុសល ៖ សំនួរចុងក្រោយទាក់ទងនឹងរដ្ឋាភិបាលបច្ចុប្បន្ន តើលោកពូយល់ថា គោលនយោបាយផ្សះផ្សារបស់រាជរដ្ឋាភិបាលមកទល់ក្នុងពេលនេះ បានសម្រេចបានជោគជ័យទេ បានកម្រិតណា តិចឬក៏ច្រើន ពី១ដល់៩ ក្នុងការផ្សះផ្សា យកតំបន់នេះកដោយ ប៉ៃលិនក៏ដោយដាក់ទៅជាផ្នែកមួយនៃប្រទេសទាំងមូល ។ ចង់និយាយថា ទាក់ទងនឹងសំនួរដើមបំផុតរបស់ខ្ញុំដែលខ្ញុំសួរ ថាតើយើងជាមនុស្សមួយហើយឬនៅ? យើងផ្សះផ្សាហើយអស់ឬនៅ? ពូថានៅថាមានច្បាប់ខាងក្នុងមើលទៅហាក់ដូចជាមាន ប៉ុន្តែវានៅមានមិនទាន់ផ្សះផ្សាពេញទំហឹង ។ តើយើងត្រូវធ្វើម៉េចទៅដើម្បីឲ្យមានការផ្សះផ្សា?

ចាន់ ៖ អានឹងជាគោលបំណង និងទស្សនៈដែលខ្ញុំដឹង ថាប្រជាជននៅតំបន់ប៉ៃលិន ដូចជាតំបន់ព្រះវិហារអី តំបន់យើងអន្លង់វែងនេះ ក្នុងការផ្សះផ្សាក៏នៅស្រពិចស្រពិលមួយចំនួនដែរ ។ ស្រពិចស្រពិលយ៉ាងម៉េច ទី១គេចាប់លេខ០១ ០២ វានៅមានលេខ០ប៉ុន្មានទៀត អានឹងអ្នកស្រុក ប្រជាជនធម្មតាគេអត់មានភ័យមានភិតអីទេ សំខាន់មានតួនាទីពីសម័យប៉ុល ពត គេមានការព្រួយបារម្ភ អានឹងខ្ញុំយល់ខ្ញុំបានចូលរៀន អភិបាលស្រុកគាត់ណែនាំ ។ គាត់ថា អានឹងមិនបាច់ភ័យមិនបាច់ព្រួយឈប់ហើយ ។ ប៉ុនអ្នកដែលមានខ្លួន គេមិនទាន់អស់ចិត្ត អានឹងគេនៅព្រួញអារម្មណ៍របស់គេនៅតែស្រពិចស្រពិលរឿងនឹងដែរ ។ អានឹងមិនទាន់ចប់សព្វគ្រប់ទេ រឿងផ្សះផ្សាជាតិ វានៅបុគ្គលខ្លះដែលមានអំណាចពីដើមមក ។ វាមិនដឹងអញគេចោតប្រកាន់ពីរឿងអី ដឹកនាំជំនាន់នោះខ្លះធ្វើស្រុកទៅ ខ្លះធ្វើឃុំទៅ ។ មកដល់ដំណាក់កាលរបបហ៊ុន សែន គាត់មានតុលាការកាត់ក្តី កាត់

អីនឹង គាត់ភ័យដែរនឹង ហើយចំពោះខ្ញុំអត់ភ័យ ខ្ញុំនិយាយត្រង់ចឹងម៉ង។ ខ្ញុំឆ្លើយតាមដំណើរខ្ញុំបើនិយាយទៅ ខ្ញុំឃើញម៉េចថាចឹង។

កុសល : បាទ! អរគុណច្រើន លោកពូមានភ្ញៀវ ខ្ញុំអរគុណច្រើន។ ហើយចាំមើលខ្ញុំចុះធ្វើការម៉ាថ្ងៃ២ថ្ងៃទៀតចឹង ពូដូចថាបើកឲ្យខ្ញុំយល់ដឹងច្រើន ខ្ញុំគិតថាទៅមុខទៀតល្អខ្ញុំអាចជួបអ្នកផ្សេងៗ។ ពូអាចឲ្យឈ្មោះម្នាក់ ២នាក់ទៀត ដែលខ្ញុំអាចជួបសួរបាន អ្នកចាស់ៗពីមុនមក។

ចាន់ : ទេ! តាំងពីថ្ងៃនឹងមក ពិបាកឲ្យឈ្មោះ សុទ្ធតែប្រជាជនធម្មតាមិនដឹងគេឆ្លើយរបៀបម៉េច

កុសល : អ្នកដែលចេះនិយាយច្រើន។

ចាន់ : អ្នកចេះនិយាយៗគេទៅធ្វើការឆ្ងាយអស់ហើយ។

កុសល : រកនឹកក្រែងមានម្នាក់ ២នាក់?

ចាន់ : ចាំដល់ថ្ងៃនឹងម៉ង ចាំឆ្អឹះយកម៉ង។

កុសល : ចឹងស្អែកខ្ញុំមកវិញ?

ចាន់ : ស្អែកខ្ញុំអតបានចូលរួម ជាប់ការងារ។

កុសល : ជាប់ការងារ ចឹងបើឲ្យឈ្មោះឲ្យហើយ បើសិនពូនឹកឃើញ?

ចាន់ : ខ្ញុំមិនដឹងឲ្យពីណា។

កុសល : ចុចអ្នកណាមួយដែលអាចដឹង អាចចេះនិយាយ។

ចាន់ : ពិបានសន្និដ្ឋានដែល អាស្ថានភាពសព្វថ្ងៃវាចិត្តខុសពីមុន។

កុសល : ចុះពេលដែលពូទៅភ្នំពេញ តែម្នាក់ឯង?

ចាន់ : ទៅគ្នាប៉ុន្មាននាក់២នាក់។

កុសល : ចុះអនុភូមិទៅដែរ?

ចាន់ : អនុភូមិទៅ។

កុសល : ចុះខ្ញុំជួបគាត់បាន?

ចាន់ : ជួបបានតើ។

កុសល : គាត់ឈ្មោះអី?

ចាន់ : ឈ្មោះ សៅ សំ។

កុសល : ផ្ទះគាត់នៅណា?

ចាន់ : ផ្ទះគាត់នៅចុង ជាប់ទំនប់។

កុសល : មានលេខទូរស័ព្ទគាត់?

ចាន់ ៖ អឺ! ខ្ញុំពិបាកប្រាប់ណាស់ ទូរស័ព្ទចុចមិនដែលចូលផង ។

កុសល ៖ ខ្ញុំទៅរកគាត់ នៅជាប់ទំនប់?

ចាន់ ៖ ទៅទីផ្លូវកុំពិបាកបត់ទៅណា ទៅត្រង់តែម្តង កុំបត់ឆ្វេង បត់ស្តាំ ទៅដល់ឃើញផ្ទះគាត់នៅចុងពូចគេ ។

កុសល ៖ អត់បានថតរូបជាមួយគ្នា ចាំមកលើកក្រោយ ។

«ចប់»